**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍ**
**តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**
**ខេត្តក្រចេះ**
**ស្រុកស្នួល**

# របាយការណ៍ស្តីពីការរៀបចំទិន្នន័យដើមគ្រា នៃការអភិវឌ្ឍសមត្ថភាព រដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់ស្រុកស្នួល

## ១.ប្រវត្តិ:

ផែនការអនុវត្តរយៈពេលបីឆ្នាំ(ផអ៣) គឺជាផែនការគាំទ្រការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល។ ផែនការនេះផ្តោតសំខាន់ទៅលើការរៀប ចំឡើងនូវរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រង រួមជាមួយនឹងការបង្កើត និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ អោយក្លាយទៅជាស្ថាប័នសម្រាប់អភិបាលកិច្ចមូលដ្ឋាន និងកិច្ចអភិវឌ្ឍមូលដ្ឋានប្រកបដោយ ប្រសិទ្ធិភាពនិងភាពស័ក្តសិទ្ធិក្នុងការអនុវត្តអាណត្តិរបស់ខ្លួនដោយរួមបញ្ចូលទាំងការផ្តល់សេវាសាធារណៈ ស្របតាមគោលការណ៍នានា នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ នាពេលបច្ចុប្បន្ននេះ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងសំខាន់ៗនៃរដ្ឋបាលថ្នាក់នេះត្រូវបានរៀបចំឡើងវិញនិងកំពុងត្រូវបានដាក់អោយដំណើ រការជាបណ្តើរៗក្នុងស្ថានភាពមួយដែលមានតំរូវការយ៉ាងខ្លាំងផ្នែកអភិវឌ្ឍន៍ធនធានមនុស្សនិង សមត្ថភាព។ អាស្រ័យហេតុនេះ កិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាព គឺជាកត្តាសត្យានុម័តក្នុងការកំណត់ពីភាពជោគជ័យ នៃការងារកំណែទម្រង់នៃរដ្ឋបាលថ្នាក់ ក្រុង ស្រុក ខណ្ឌ ។

ផ្អែកតាមផអ៣នៅចុងឆ្នាំ ២០១៣ បុគ្គលិក និងអ្នកដឹកនាំទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាល ក្រុង ស្រុក ខណ្ឌ នឹងមានសមត្ថភាពប្រើប្រាស់អោយអស់លទ្ធភាពនូវសក្តានុពល របស់ខ្លួនដើម្បីអនុវត្តតួនាទី និងការទទួលខុស ត្រូវដែលបានផ្ទេរអោយប្រកបដោយប្រសិទ្ធភាព ។

ក្នុងស្ថានភាពចំពោះមុខនេះដែលសមត្ថភាពរដ្ឋបាលក្រុងស្រុកខណ្ឌនៅមានកំរិតនៅឡើយ សម្រាប់ការអនុវត្តតួនាទីភារកិច្ចដូចដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់អនុវត្តច្បាប់នេះ ។ ហេតុនេះការកិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌអនុវត្ត ផអ៣ នឹងត្រូវរៀបចំឡើងយ៉ាងច្រើនជាបន្តបន្ទាប់ ។

ដើម្បីបំពេញតម្រូវការនៅថ្នាក់មូលដ្ឋាន ក្នុងការលើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាព របស់រដ្ឋបាល ស្រុក ការចុះប្រមូលទិន្នន័យដើមគ្រា ត្រូវបានធ្វើនៅស្រុកស្នួល ។

ស្រុកស្នួល មានទីតាំងនៅភាគប៉ែកឦសាន្ត នៃប្រទេសកម្ពុជា មានចំងាយផ្លូវប្រវែង ៨៤ គ.ម ពីទីរួមខេត្តក្រចេះ និងមានឃុំចំនួន ០៥ ឃុំ ភូមិ ចំនួន ៣៦ ភូមិ ។ ក្រុមប្រឹក្សាស្រុកមានចំនួន ១៥ នាក់

ក្នុងនោះស្រី៣នាក់គណៈអភិបាលមានចំនួន០៥នាក់ក្នុងនោះអភិបាលរងជាស្ត្រី ០១ នាក់ ។ បច្ចុប្បន្ននេះរដ្ឋបាលសាលាស្រុកស្ទួលមានមន្ត្រីចំនួន ១៦ នាក់ ស្រី ០៤ នាក់ ហើយស្រុកស្ទួលពុំទាន់មាននាយករដ្ឋបាលនៅឡើយ ឯនាយករង ០១ នាក់ ព្យួរការងារ។

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុមានមន្ត្រីចំនួន ០៥ នាក់ ស្រី ០២ នាក់
- ការិយាល័យផែនការ និងគាំទ្រឃុំ មានមន្ត្រីចំនួន ០៥ នាក់ ស្ត្រី ០១ នាក់
- ការិយាល័យអន្តរវិស័យមានមន្ត្រីចំនួន ០៥ នាក់ ស្ត្រី ០១ នាក់។

**២.គោលបំណង:**

គោលបំណងនៃការចុះប្រមូលទិន្នន័យដើមគ្រាអំពីសមត្ថភាពរបស់រដ្ឋបាលស្រុកស្ទួលគឺដើម្បីធានាអោយមានទិន្នន័យមូលដ្ឋានពាក់ព័ន្ធសមត្ថភាពរបស់រដ្ឋបាលស្រុកដែលជាមូលដ្ឋានសម្រាប់ការកំណត់តម្រូវការនិងការវាស់វែងពីភាពរីកចម្រើននៃសមត្ថភាពរបស់រដ្ឋបាលស្រុកក្នុងអំឡុងពេលអនុវត្តនិងនៅពេលបញ្ចប់ ជអ៣ នៃកម្មវិធីជាតិ ។

**៣-វិធីសាស្ត្រ:**

| វិធីសាស្ត្រ | ឧបករណ៍ |
|---|---|
| - ពិនិត្យឯកសារដែលមាន(បញ្ជីសំណួរ)<br>- ការសង្កេតផ្ទាល់(ចុះមូលដ្ឋានគោលដៅនៅសាលាស្រុកស្ទួល)<br>- សម្ភាសន៍(បុគ្គល ក្រុម និងអ្នកផ្តល់ព័តិមានសំខាន់ៗ)<br>- ការបំពេញបញ្ជីសំនួរដោយខ្លួនឯង<br>- ការពិភាក្សាជាក្រុម។ | - បញ្ជីសំណួររៀបចំដោយថ្នាក់ជាតិ<br>- បញ្ជីសំណួរសម្រាប់សម្ភាសន៍បុគ្គល<br>- បញ្ជីសំណួរសម្រាប់ការពិភាក្សាក្រុម<br>- ទម្រង់និងគំរូសម្រាប់សរសេររបាយការណ៍ ។ |

**៤-លទ្ធផលនៃការអង្កេតទូទៅ**

ការអង្កេតទូទៅ

ក្រុមប្រឹក្សាស្រុកស្ទួល បានរៀបចំកិច្ចប្រជុំសាមញ្ញដោយពិភាក្សាជាក្រុម និងបុគ្គល ណែនាំអោយគណៈអភិបាលចាត់ចែងមន្ត្រី ដើម្បីបំពេញបញ្ជីសំណួរដែលបានណែនាំដោយក្រុមការងារ និងបានរៀបចំទទួលក្រុមការងារចុះប្រមូលទិន្នន័យដើមគ្រា សម្ភាសន៍ផ្ទាល់ទាក់ទងនឹងសមត្ថភាពរបស់មន្ត្រី រដ្ឋបាលស្រុក។ ជាមួយនេះការកត់សម្គាល់មួយទៀតបានបង្ហាញពីភាពយកចិត្តទុកដាក់ និងការលះការបង់ខ្ពស់របស់រដ្ឋបាលស្រុកស្ទួល ក្នុងការចំណាយពេលវេលាដើម្បីចូលរួមផ្តល់ព័តិមានដល់ក្រុមការងារចុះប្រមូលទិន្នន័យក្នុងន័យរួមចំណែកការអនុវត្តកម្មវិធីជាតិ តាមបែបបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ។

**ចំណុចខ្លាំង**

- ក្រុមប្រឹក្សាទាំងអស់មានការចូលរួម។
- មានការទទួលបដិសណ្ឋារកិច្ចល្អពីក្រុមប្រឹក្សា និងគណៈអភិបាល។
- ក្រុមគោលដៅយល់ពីគោលបំណងសម្រាប់ដំណើរសម្ភាសន៍ ។

- ការណាត់ជួបក្រុមគោលដៅទាន់ពេល ។
- ទីតាំងនៃការធ្វើសម្ភាសន៍សមស្រប។
- ពន្យល់ពីវិធីសាស្ត្រ ដើម្បីធ្វើឲ្យងាយក្រុមគោលដៅបានឆ្លើយតប។

**ចំណុចខ្សោយ**

- ក្រុមប្រឹក្សាពុំទាន់យល់ពីការអនុវត្តការងាររបស់ គ.ក.ស.ក។
- មន្ត្រី POC មិនសូវមានភាពម្ចាស់ការ និងការទទួលខុសត្រូវលើការងារ។
- ការអនុវត្តពីតួនាទី និងភារកិច្ចរបស់មន្ត្រីរដ្ឋបាលសាលាស្រុកពុំទាន់បានល្អ ។
- មន្ត្រីសាលាស្រុកមិនសូវមានការចូលរួម។
- ការសម្ភាសន៍ត្រូវណាត់ជួបពេលបន្តបន្ទាប់។

**៥-អនុសាសន៍**

ដើម្បីរួមចំណែកដល់ការលើកកម្ពស់ប្រសិទ្ធភាពការងារ និងការធ្វើអោយប្រសើរនូវការអនុវត្ត តួនាទី និងភារកិច្ចរបស់រដ្ឋបាលស្រុកស្ទួល ក្រុមប្រឹក្សាស្រុកគួរយកចិត្តទុកដាក់ទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

1. គួរពង្រឹងយន្តការគាំទ្រពីថ្នាក់ខេត្តដល់រដ្ឋបាលសាលាស្រុក។
2. ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ស្រុកគួរធ្វើការពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សាអំពីការងារពាក់ព័ន្ធមួយចំនួន ដូចជា ការអនុវត្តការងាររបស់ គ.ក.ស.ក លើការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំប្រចាំត្រីមាសនិងប្រចាំខែព្រមទាំងការរៀបចំផែនការថវិកាប្រចាំឆ្នាំរបស់គ.ក.ស.កការជួយគាំទ្រ គ.ក.ស.ក។
3. ខេត្តគួរបណ្តុះបណ្តាលពីនីតិវិធីថវិកា ការចាយ និងការទូរទាត់ថវិកា គ.ក.ស.ក អោយបានរហ័សតាមដែលអាចធ្វើបាន។
4. រដ្ឋបាលសាលាស្រុកស្ទួល គួរពង្រឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលអោយបានល្អជាងនេះ។
5. គណៈអភិបាលស្រុកស្ទួល គួរពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់មន្ត្រីស្រុកឡើងវិញ ។

ស្ទួល,ថ្ងៃទី 25 ខែ មេសា ឆ្នាំ២០១២

**អ្នកធ្វើរបាយការណ៍**

សាម ណាល់